ការសម្ភាសរបស់តាសឿងឈួន

ក៏ អ្នកសម្ភាស ឡេងធារី ខ៏ អ្នកត្រូវគេសម្ភាសឈ្មោះ សឿងឈួន
ក៏ ហ៊ីនឡេង(អ្នកជិតខាង)

ក៏ ខេចឹងអើ...ពីដំបូងសូមអរគុណតាដែលបានឱ្យពួកខ្ញុំ
មកធ្វើការសម្ភាសហើយអើ...ថ្ងៃនេះខ្ញុំមកសម្ភាសតាគឺនៅអើ...នៅថ្ងៃទីដប់..១២ខែ
កក្កដាឆ្នាំ២០១៨។ ហើយខ្ញុំអ្នកសម្ភាសតាខ្ញុំឈ្មោះឡេងធារីហើយតាឈ្មោះអីដែរតា?
ឈ្មោះពេញ?
ខ៏ អឺ..ឈ្មោះសឿងឈួន។
ក៏ ឈ្មោះអីតា?
ខ៏ ឈ្មោះសឿងឈួន។
ក៏ សឿងឈួន? ហើយអើ...នៅ...នៅផ្ទះតានៅសព្វថ្ងៃហ្នឹងភូមិឃុំអីតា?
ខ៏ ភូមិក្រឡា ឃុំអំពិល ស្រុកកំពង់ចាម ខេត្តកំពង់ចាម។
ក៏ ហើយអឺ..ហើយតាអឺ..ដូចជាចាំថ្ងៃខែកំណើតកើតខ្លួនឯង?
ខ៏ ខ្ញុំមើលវាអាយុឥឡូវចិតសិបប្រាំមួយ ចិតប្រាំពីរហើយឆ្នាំមមែ។
ក៏ ចុះឆ្នាំបារ៉ាំងអត់ចាំហ៎ាតា?
ខ៏ អត់ចាំ។
ក៏ ចាំតាឆ្នាំមមែ?
ខ៏ បាទ!
ក៏ ហើយតាកើតស្រុកកំណើតនៅខាងណាវិញ?
ខ៏ ខ្ញុំនៅស្រុកហ្នឹង ភូមិហ្នឹងតាហ្នង ភូមិក្រឡាយើងហ្នឹង។
ក៏ អ...ចឹងកើតនៅហ្នឹង រស់នៅហ្នឹងរហូតមកដល់សព្វថ្ងៃ?
ខ៏ នៅទាល់សព្វថ្ងៃ។
ក៏ ហើយតាដូចមានបងប្អូនប៉ុន្មាននាក់ដែរ?
ខ៏ សព្វថ្ងៃនៅតាម្នាក់ឯងទេគេងាប់អស់ហើយ ប្អូនក៏ងាប់
បងៗក៏ងាប់អស់ហើយ។
ក៏ ចាស! ប៉ិនគ្រាន់ថាក្នុងក្រុមគ្រួសារហ្នឹងបងប្អូនប៉ុន្មានអ្នកសរុប?
ខ៏ សរុបពីមុនមកប្រាំមួយ ប្រាំពីរនាក់ហាស។
ក៏ ប្រាំពីរនាក់ទាំងតា?
ខ៏ បាទ!
ក៏ តាកូនទីប៉ុន្មាន?
ខ៏ ខ្ញុំទីបួន ទីប្រាំហើយខ្ញុំ។
ក៏ ចាស!
ខ៏ បងៗគេងាប់អស់ទៅហើយ។
ក៏ ហើយចឹងពួកគាត់ស្លាប់អស់ហើយ?
ខ៏ បាទ!
ក៏ ដោយសារស្លាប់ដោយសារអីតា?
ខ៏ ហ៎..ដោយសារចាស់ហើយចិត ប៉ែតអស់ទៅហើយ។
ក៏ ចាស! តាចាំឈ្មោះពួកគាត់ទាំងអស់គ្នាហ៎?
ខ៏ ចាំ!
ក៏ ទាំងប្រាំមួយនាក់ហ្នឹងរៀបរាប់ពីទីមួយរហូតមកតា?
ខ៏ តាមីតាមី។
ក៏ ឈ្មោះពេញគាត់ចាំហ៎?
ខ៏ ឈ្មោះតាមីហ្នឹងហើយស្រីទៀតយាយកេនបានមកខ្ញុំមួយទៀតម
កចាមចាមហើយបានមកខ្ញុំហ្នឹងឈួន
អស់ហើយនៅតាចៅៗហើយកូនប៉ុន្មាននាក់នៅជាមួយ។

ក៖ ចាស!
ហើយតាអឹម...បងប្អូនអីដូចមានអនុស្សាវរីយ៍អីជាមួយគ្នាពីក្មេងពីអីមក?
ខ៖ ក្មានទេ។
ក៖ ដូចរឿងធ្វើស្រែឬក៏ធ្លាប់ពីក្មេងទៅលេងអីធ្លាប់លេងអីដែរពីក្មេងមកមាន?
ខ៖
ហេស...ក្មានលេងអីទេធ្វើការនៅមុខរោងចក្រអីមុនខ្ញុំនៅធ្វើណុងពីដំបូងខ្ញុំនៅ
ធ្វើរោង ចក្រ។
ក៖ ចាស! ចុះជំនាន់តាក្មេងៗគេចូលចិត្តលេងអីតា?
ខ៖ ពីដើមមក?
ក៖ ពីដើមមក។
ក៖ លេងបោកចំបាប់ លេងឈូង។
ខ៖ លេងលោតអន្ទាក់ទៅ បោះឈូងទៅ លេងអង្គញ្ញទៅតាប៉ុណ្ណឹង។
ក៖ ចាស!
ខ៖ វាក្មានល្បែងអីដូចឥឡូវណា។
ក៖ មានរត់ខ្លែងអីដែរហេស?
ខ៖ ហូរខ្លែងរត់តាំងពី.. រត់ដួលម៉េស។
ក៖ លេងរត់ខ្លែងដែរតាហ្នឹ?
ខ៖ លេង...ពីតូចៗមានតាចុង។
ក៖ ចាស!
ខ៖ ខែចេញខ្យល់មកពីដើងមកហ្នឹង។
ក៖ ហើយអឹម...ដូចឪពុកម្តាយតាគាត់ឈ្មោះអី?
ខ៖ ម្តាយខ្ញុំហ្នឹសយាយស៊ាន តាសឿង តាសឿងយាយស៊ាន។
ក៖ ឈ្មោះពេញគាត់ត្រកូលស្គាល់ត្រកូលគាត់តា?
ខ៖ តាហ៊ីល...ហ៊ីលសឿង។
ក៖ ហ៊ីលសឿង។
ក៖ ហ៊ីលសឿង?
ខ៖ យី...យីស៊ាន។
ក៖ យីស៊ាន?
ខ៖ ខាងម្តាយហើយយី...យីស៊ាន។
ក៖ តាចាំគាត់កើតហ៎?
ខ៖ អត់ចាំទេនាងគាត់ខូចតាំងពីខ្ញុំមិនទាន់ដឹងផង។
ក៖ អញ្ចឹងគាត់...គាត់ខូចពេលគាត់ខូចតាអាយុប៉ុន្មាន?
ខ៖ អាយុប្រហែលជា៩ឆ្នាំប៉ុណ្ណឹងស្រពិចស្រពិល ថាប្រហែលប្រាំ ប្រាំមួយឆ្នាំប៉ុណ្ណឹង។
ក៖ ពេល...ពេលគាត់ខូចហ្នឹងគាត់អាយុប៉ុន្មានតា?
ខ៖ ឪពុក
ឪពុក៨៧មកម្តាយទៀត៨៧ហើយជីតាអត់ដឹងសោះខ្ញុំមិនដឹងថីបានគាត់ខូច។
ក៖ អ៉...
ក៖ តាគាត់ស្លាប់តាំងពីតានៅគាត់អាយុប្រាំមួយ ប្រាំពីរឆ្នាំអីម៉េសនៀក
ប៉ែតជាងហ្នឹងឪពុកគាត់ទេ។
ខ៖ ម្តាយក៏បាន៨៧ ឪពុកក៏បាន៨៧។
ក៖ ហើយចឹងតានៅតាំងពីអាយុបួន
ប្រាំឆ្នាំម៉េសស្លាប់ដល់ពេលហើយ...ដល់ពេលឪពុក...
ក៖ ហ៎អាណុងជីតាគាត់ហ៎?
ខ៖ ជីតា។
ក៖ ជីតាហ៎? អ៉...
ខ៖ ឪពុកខ្ញុំប្រហែលប្រាំ ប្រាំមួយឆ្នាំហើយហ្នឹ។
ក៖ បាទ!

ខ៖ តាប៉ុណ្ណឹងប្រាំមួយឆ្នាំអី។
ក៖ ចឹងប្រាប់ឈ្មោះមិញហ្នឹងឈ្មោះជីតា ជីដូនជីតាឬក៏ឈ្មោះឪពុកម្តាយ?
ខ៖ ឪពុកម្តាយ ឪពុកៗតាមួយទៀតត្រូវឈ្មោះតាហ៊ីល ហ៊ីលសឿង
ហើយម្តាយស៊ានអ៉ីយ៉ី ស៊ាន។
ក៖ យ៉ីស៊ាន? ហើយអី...ចុះៗឪពុកម្តាយតាគាត់ស្លាប់ពេលណាដែរ?
ខ៖ ហ្នឹងស្លាប់មកបន្ទាន់ៗគ្នាហ្នឹងសម័យ...។
ក៖ អត់ទេ។
ខ៖ ហាស!
ក៖ តាសឿងគាត់ស្លាប់ប្រហែលជាសម័យប៉ែតជាងអីទេ។
ខ៖ ហ៎ដូចដាច់ហើយហ្នឹង?
ក៖ ដាច់ហើយប៉ែតជាងទេ។ បាទ! ខ្ញុំជួយកប់នៅចម្ការអីលិចនោះ។
ខ៖ ណុងហើយ អ៉ា..អ្នែងដូចច្បាស់ដែរ។
ក៖ កាលគាត់ខ្ជូចហ្នឹងអាយុប៉ុន្ថានតា?
ក៖ ប៉ែតជាងហើយតាសឿងនោះ។
ខ៖ ប៉ែតជាងហាស។
ក៖ ប៉ែតជាង? គាត់ស្លាប់ដោយសារចាស់ណើរ ចាស់ជរា?
ខ៖ ចាស់ជរាទេ។
ក៖ ចាស់ជរា។
ក៖ ហើយចុះម្តាយ?
ខ៖ ម្តាយក៏ចឹងដែរ ក្ខានឈឺអីគាត់ជរាចាស់ទុំអាណុងគេហៅចាស់ទុំហាស។
ក៖ ខ្ជ្ជ ចាំកាលណុងដាក់អាទេះហែរផងកាលណុងហាស។
ខ៖ អឺ...
ក៖ ហើយតាដូចពី
ក្មេងអីមកដូចរស់នៅជាមួយឪពុកម្តាយអីចាំដូចមានអនុស្សាវរីយ៍អីជាមួយពួក
គាត់ហ៎តា?
ខ៖ ដូចអត់មាន។
ក៖ គាត់ធ្លាប់បង្ហាត់បង្រៀនអីខ្លះដែរក្បាច់គុណលឬក្តោអីដែរ?
ខ៖ មានកាលនៅវត្តនៅ។
ក៖ ធ្លាប់ទៅនៅវត្តដែលតាណើរ?
ខ៖ នៅ!
ក៖ អាយុប៉ុន្ថានទៅនៅវត្ត?
ខ៖ អាយុជាងដប់ឆ្នាំប្រហែលដប់ពីរ ដប់បីតាប៉ុណ្ណឹង។
ក៖ ទៅៗ...ធ្វើកូនសិស្សលោកក៏មិចដែរទៅវត្តហ្នឹង?
ខ៖ ទៅសិស្សលោក ទៅបង្រៀនលោកបង្រៀន។
ក៖ ធ្វើជាសិស្សលោកផង ទៅជារៀនអក្សរពីលោកផងកាលគាត់ពីដើមនោះ
ព្រោះថាសម័យគាត់នៅតូចៗចឹងមិនសូវមានសាលារៀនទេ។
ខ៖ នៅតូចហ្នឹងនៅតូចមែនទែនទៅនៅវត្តត្រង់កោះសូទិនហ្ន៎នៅ។
ក៖ អូ...វត្តកោះសូទិនយើងនេះហ្ន៎?
ខ៖ បាទ!
ក៖ ហើយទៅនៅណុងបានប៉ុន្ថានឆ្នាំតា?
ខ៖ ហឹមនៅមិនទៀងតាខែហ្នឹងគាត់ទៅយកមកឱ្យមើលគោមើលក្របីវិញហ៎។
ក៖ អ៉ា...
ខ៖ ជួយមើលគោមើលក្របី។
ក៖ ទៅនៅវត្តតាខែទំនេរពីស្រែទៅ។
ខ៖ រួចទៅគាត់ជូនទៅវិញ។
ក៖ អ៉ា...
ខ៖ ដល់ជ្រូកកាត់គាត់ទៅយកមកឱ្យជួយជ្រូតអីចឹងទៅ។

ក៖ ហើយទៅហ្នឹងដូចទៅបម្រើលោកបាយទឹកអីចឹងទៅអីក៏មិចតា?
ខ៖ អា...ហ្នឹងទៅបម្រើតាមលោកទៅទ្រង់បានទៅយកវេនតាមផ្ទះ។
ក៖ ហើយអឹម...
ខ៖ ថ្ងៃអញ្ចឹងទៅបាយរួចលោកបង្រៀន។
ក៖ ដូចឪពុកម្តាយតាអីគាត់មនុស្សមិចដែលតាស្លូត កាច?
ខ៖ ហ៎...មិនកាចមិនអីទេ ស្លូតទេ។
ក៖ ស្រឡាញ់កូនចៅ។
ខ៖ ស្រឡាញ់ណាស់ គាត់ស្រឡាញ់កូន។
ក៖ ដល់ពេលតាយាយពីរឿងចូលសាលារៀនវិញបានទៅរៀននៅសាលាទៅអីដែរ?
ខ៖ អត់!
ក៖ ក៏រៀនតានៅវត្តទេ?
ខ៖ អត់សោះសាលា ត្រឹមតានៅវត្ត។
ក៖ តារៀននៅវត្តនៅហ្នឹងចេះអានចេះសរសេរហាតាណើរ?
ខ៖ ចេះបន្តិចទេមិនជាខ្លាំងទេ។
ក៖ ចុះធម៌អីដែលរៀន?
ខ៖ រៀនដែរ ធម៌ថ្នាយបង្គំរៀនមួយចប់។
ក៖ ចាស...ហើយអឹម...ចុះរៀនភាសាអីផ្សេងអត់មានហ៎តាណើរ?
ខ៖ អត់មានហេស។
ក៖ តាខ្មែរមួយ?
ខ៖ តាខ្មែរ។
ក៖ ហើយ...ក្រោយមកទៀតដូចអឺ...តាអីកាលរៀបការអីតារៀបការពេលណាដែរ?
ខ៖ កាលពីខ្ញុំនៅអាយុ២២មក ឥឡូវចិតជាងចិតប្រាំមួយចិតប្រាំពីរហើយ។
ក៖ អញ្ចឹងអត់ចាំឆ្នាំហេតាណើរ?
ខ៖ អត់ចាំ។
ក៖ ហ់យពេលតាការហ្នឹងដូចម៉ែឪគាត់រៀបការឱ្យឬក៏...?
ខ៖ ការរៀបការឱ្យ។
ក៖ ប៉ុន្តែដូចអឺ...គាត់អ្នកផ្សំផ្គុំដែលស្គាល់គ្នាពីមុនមក?
ខ៖ ទេគាត់ផ្សំផ្គុំត្រឹមត្រូវ។
ក៖ ហើយតាស្គាល់ៗខាងស្រីហ៎ពីមុនការហ្នឹងដែលធ្លាប់ជួបមុខជួបអី?
ខ៖ អឺ...ឪពុកម្តាយខាងណុងហ៎...។
ក៖ ដែលធ្លាប់...
ខ៖ ហេ..គាត់នៅឆ្ងាយ។
ក៖ ដែលធ្លាប់នាំទៅមើលល្ខោនអីដែរ Concertអីដែរ?
ខ៖ មិនដែលទេ បើត្រឹមភ្ជុំអ៊ីពីដើមទៅ។
ក៖ ប៉ុនអញ្ចឹងពីមុនការហ្នឹងស្គាល់គ្នាដែរ ជួបមុខធ្លាប់ជួបមុខគ្នាដែរ?
ខ៖ បងអ្នកនីដូនមួយហ្នឹង។
ក៖ ហើយការហ្នឹងមានជំនួនមានអីឱ្យគេ?
ខ៖ មានតាជំនាន់ណុង។
ក៖ ចំនួនហ្នឹងជាលុយក៏មិចតា?
ខ៖ លុយផ្សាំងទៅហើយជំនួននំអន្សមអាហ្នឹងដូចថាឱ្យចាស់ដឹងក្មេងឮហាស
នំអន្សមអីទៅ។
ក៖ ហើយដូចលុយហ្នឹងជំនាន់ណុងប៉ុន្មានទៅតាជូនគេ?
ខ៖ កាលណុងដូចជាប្រាំពីរពាន់។
ក៖ ប្រាំពីរពាន់រៀល?
ខ៖ លុយខ្មែរហ្នឹង។
ក៖ ស្មើឥឡូវស្មើប៉ុន្មានទៅ?

ខ៖ ហ៎! ឥឡូវដឹងប៉ុន្មានទេផ្លែហាលុយកាលណុង
ចាយតាំងពីក្រដាសលុយកាក់ម៉ែស។
ក៖ ចាស!
ខ៖ កាលណុងបង្ហាប់មាសផង អោយគេបីដីទៀត។
ក៖ អូ...មានលុយផងមានមាសផង?
ខ៖ បាទ!
ក៖ ហើយមាសមួយដីប៉ុន្មានកាលណុងតា?
ខ៖ មួយដីបីរយ ឬនរយហ្នឹង។
ក៖ អឹម...ហើយអី...ដល់ពេលហើយតារាល់ថ្ងៃមានកូនប៉ុន្មាននាក់ការហើយ?
ខ៖ ប្រាំ!
ក៖ ប្រាំនាក់?
ខ៖ ប្រុសមួយស្រីបួន។
ក៖ ប្រុសមួយស្រីបួន? តាចាំឈ្មោះគាត់ទាំងអស់ហេឈ្មោះអីខ្លះ?
ខ៖ មួយឈ្មោះផ្ទូ។
ក៖ គាត់អាយុប៉ុន្មានហើយតាឥឡូវ?
ខ៖ ឥឡូវសែ(៥០) សែហើយបងគេបង្ហស់ទៀត បានមកអាជា អារិតហ្នឹងហាស។
ក៖ បាទ!
ខ៖ ហើយមួយទៀតកាផ្ទ បានមកកាផលមីពៅនោះមីផា ប្រាំ។
ក៖ ពួកគាត់ការមានគ្រួសារបែកផ្ទះអស់ហាណើរ?
ខ៖ អើ...បែកអស់ហើយ ខ្លះគេមានចៅទៀត។
ក៖ តាមានចៅប៉ុន្មាននាក់?
ខ៖ ចៅសព្វថ្ងៃនៅជាមួយពីរនាក់ បីនាក់តាំងនៅរៀន មិនដឹងទៅណាទេមិញ។
ក៖ ហើយអឹម...ប្រពន្ធតាគាត់ឈ្មោះអី?
ខ៖ អ៊ីម!
ក៖ ឈីម?
ខ៖ អ៊ីម។
ក៖ អ៊ីម? ស្អីអ៊ីមតា?
ខ៖ ឡាយ។
ក៖ ឡាយអ៊ីម? គាត់នៅរស់ក៏គាត់ស្លាប់ហើយតា?
ខ៖ យាយហ្នឹងហ្ន?
ក៖ ចាស!
ខ៖ នៅ!
ក៖ គាត់អាយុប៉ុន្មានហើយឥឡូវ?
ខ៖ ផិតប៉ែតហើយណ៎ា ប៉ែតប្រាំបី ប៉ែតប្រាំបួនហើយណ៎ា។
ក៖ អូ...
ខ៖ ចិតប្រាំបីចិតប្រាំបួនហើយ ឆ្នាំមើល...ឆ្នាំរោង។
ក៖ ឆ្នាំរោង?
ក៖ បងតាពីរឆ្នាំចិតប្រាំបួនហើយអញ្ចឹង?
ខ៖ ហឹម...
ក៖ តាចិតប្រាំពីរយាយបងពីរឆ្នាំចិតប្រាំបួន?
ខ៖ ចិតប្រាំបួន ប៉ែតហើយ។
ក៖ ហើយតាអឹម...ជំនាន់ប៉ុលពតមិចដែរ?
ខ៖ ជំនាន់ណុងខ្ញុំដូចជាគ្មានបានធ្វើអីទេគេឱ្យនៅចង្ក្រានបាយ ដាំស្លឱ្យ...
ក៖ ចុងភៅ។
ខ៖ ចុងភៅឱ្យគេស៊ី។
ក៖ នៅ...នៅណាវិញពេលណុងគេជម្លៀសឱ្យទៅណាអត់ទេក៏នៅ?
ខ៖ ពេលណុងៗនោះនៅរោងបាយណុះត្បូងៗ។នៅក្បែរផ្ទះអាជុនណុង។

កៈ បាទ!
ខៈ ផ្លាស់ពីនេះទៅណុង។
កៈ ហើយអឺម...ចុងភៅហ្នឹងចុងភៅឱ្យខាងណាឱ្យកងទាហានឬក៏...?
ខៈ អត់ទេកម្មករហ្នឹង។
កៈ ឱ្យយើងតាមផ្ទះហ្នឹងហាសកាលណុងគេស៊ីបាយរួមនោះ។
ខៈ ស៊ីបាយរួម។
កៈ គេបង្កើតជារោងបាយនោះ។
ខៈ គ្មានទៅបាយផង បបរ។
កៈ គេមិនឱ្យស៊ីតាមផ្ទះខ្លួនឯង ស៊ីរួមធ្វើការរួម។
ខៈ រោងបាយណុង។
កៈ
ហើយតាអឺ...អត់ដែលទៅ...អញ្ចឹងយាយទៅមួយសម័យប៉ុលពតហ្នឹងតាធ្វើតាចុង
ភៅហេំណើរអត់ដែលគេឱ្យទៅធ្វើស្រែធ្វើអីលើកទំនប់លើកអី?
ខៈ ទៅយប់បើនេះទៅជួយដក គេឱ្យជួយដកទៀត។
កៈ ចាស!
ខៈ ហើយបើខែច្រូតរែកបាយរែកបបរអីយកទៅឱ្យគេតែប៉ុណ្ណឹង។
កៈ ចាស...ហើយជំនាន់ហ្នឹងតាម៉េចដែលវេទនាអត់ក៏..?
ខៈ ហេំ...រឿងវេទនាហ្នឹងវាហួសពីវេទនាហើយ។
កៈ វេទនាម៉េចខ្លះតា?
ខៈ
វេទនាតាំងពីហូបចុកអីហ្នឹងមាននេះណាចែកបបររែកក្រឡមរែកសម្លហ្នឹងពីររែក
ៗម្នាក់ហ្នឹងបបរទឹក
អាណិតអាតូចៗអញ្ចឹងអើ...គ្នាឃ្លានធ្វើមិចមែនដូចមនុស្សចាស់ណា
ចាស់ទៅក៏...បោចស្លឹកឈើស្លឹកព្រៃស៊ីខ្លះទៅ។
កៈ ចាស!
ខៈ ក្តាម ខ្ចងនោះដុតស៊ីខ្លះទៅ។
កៈ ហឹម..
ខៈ វេទនាដែលហ្នឹងមែនថាមិនវេទនាណា
ចាស់ៗរែកទៅរែកបបរទៅដាក់តាមផ្ទះចែករបប   ដែរ។
កៈ ហើយអឺម...តាពេលហ្នឹងការហើយហេំប៉ុលពត?
ខៈ ខ្ញុំការហើយកូនពីរ កូនបីហើយកាលជំនាន់ណុង។
កៈ ហើយចុះគេឱ្យនៅជាមួយក្រុមគ្រួសារហេំក៏បែកពីគ្នា?
ខៈ បែកៗគ្នា បើចល័តតូចៗអីគ្មាននៅជាមួយឪពុកម្ដាយណាកូនចៅ
ទៅថ្ងៃទៅកាប់ទ្រាងខែត្រអីយកមកធ្វើជី។
កៈ ហើយដូចអឺម...មួយខែអីជួបមុខគ្នាប៉ុន្មានដងអញ្ចឹង?
ខៈ ដល់ល្ងាចជុំវិញថ្ងៃបែកការងារដោយខ្លួន។
កៈ អ៎...អញ្ចឹងបានន័យថានៅផ្ទះជាមួយគ្នាអញ្ចឹងយប់ៗជួបគ្នាអញ្ចឹង?
ខៈ ជុំគ្នា។
កៈ
ហើយអឺ...តាអត់មានដូចមានសាច់ញាតិក្រុមគ្រួសារណាដែលត្រូវប៉ុលពតសម្លាប់?
ខៈ មានដែលក្មួយគេយកទៅសម្លាប់ចោល។
កៈ ក្មួយៗខាងណាតា?
ខៈ ក្មួយខាងខ្ញុំហ្នឹងតាហួង ថាវបែបទាន់ហេំទាវ?
កៈ ពីណា?
ខៈ ថាវៗកូនតាលឹមហ្នឹងហាស។
កៈ ស្គាល់ទេខ្ញុំ។
ខៈ ទាន់ហេំរត់ទៅណុងងាប់អី អណ្ដូងនៅព្រៃទទឹងហ្វូទ័ពបាញ់ងាប់។

ក៖ គាត់អត់នៅហ្នឹងផងកាលណុងហេ?
ខ៖ ហ្ន..បែកខ្ទែកគ្នា
អញទៅលើនោះបានប៉ុន្ថានពីរឆ្នាំដែរបានចុះមកដល់យើងហ្នឹងវិញ។
ក៖ កាលគាត់ស្លាប់ហ្នឹងអាយុប៉ុន្ថានតាគេសម្លាប់ហ្នឹង?
ខ៖ អាយុហ្នឹងប្រហែលជាដប់បួន ដប់ប្រាំហ្នឹងកាលណុងគេហៅចល័ត។
ក៖ ចល័ត កងចល័តកុមារ។
ខ៖ ប៉ុនណុងគេយកកាំភ្លើង អូសកាំភ្លើងគេហៅវាទៅ។
ក៖ ហើយៗម៉េចបានគេយកទៅសម្លាប់ក្មេងហ្នឹង?
ខ៖ កាលណុងគេរកប៉ុលពត ឯងចូលទៅខកចេញមិនរួចគេបាញ់។
ក៖ ហើយចុះអ្នកផ្សេងអីអត់មានហ៎ណើសមានតាគាត់មួយហ្នឹង?
ខ៖ មួយហ្នឹងទេបានដឹងថាងាប់។
ក៖ ហើយអី..ដល់ពេលរួចពីហ្នឹងមកតាធ្វើអី?
ខ៖ អូ...ជ្រើនដំណាក់កាលហាសខ្ញុំគេឱ្យឡើងភ្នោតពេលអាពត។
ក៖ មានឡើងភ្នោតទៀត?
ខ៖ ឡើងៗអាក្រោយៗហ្នឹង រួចមកបានគេឱ្យនៅរោងបាយ
អាណិតអាតូចៗទេតាស្ទាហ្នឹងមកហើយវេទនាណាស់កាលណុង។
ក៖ ហើយអី...អញ្ចឹងតាប៉ាហ្នឹងហ៎ណើរឡើងភ្នោត?
ខ៖ ឡើងភ្នោតហ្នឹងហី...។
ក៖ រោងបាយ?
ខ៖ អើ...យើងរួចភ្នោតទៅកាប់អូសយកមកឱ្យគេអ្នកចាំដុត ដុតផ្សេងទៅ។
ក៖ អញ្ចឹងទៀត?
ខ៖ អាគេហាលនោះគេហាលផ្សេងទៅ។
ក៖ អឹម...
ខ៖ ឱ្យតាឡើងទេរួចរំងាស់វិញលើគេ។
ក៖ ចុះប្រពន្ធតាគាត់ធ្វើអីពេលណុង?
ខ៖ ធ្វើដូចតាសព្វថ្ងៃហ្នឹងកម្មករគេ
អើ...គេឱ្យដកស្ទូងរួចការងាររួចទៅគេឱ្យទៅ...ដកស្ទូងថ្ងៃ។
ក៖ ចុះពេលដាច់ប៉ុលពតទៅតាធ្វើអីមកធ្វើស្រែធម្មតាវិញក៏...?
ខ៖ ធ្វើធម្មតាវិញ គេចែកដីឱ្យធ្វើ។
ក៖ ហើយអី...ដូចតាដូចពីឪពុកម្តាយមកហ៎ណ៎ា។
ខ៖ ពីឪពុកម្តាយមកស្រែគោតាប៉ុនណុង។
ក៖ ចាស!
ខ៖ អាហ្នឹងអញ្ចឹងគាត់ទៅយកមកជួយដកស្ទូងមើលគោមើលក្របី។
ក៖ អញ្ចឹងគាត់ធ្វើតាស្រែ?
ខ៖ ធ្វើស្រែ។
ក៖ ហើយពីក្មេងមកផ្ទះតានៅហ្នឹងរបៀបម៉េចផ្ទះហ្នឹង?
ខ៖ ផ្ទះតូច ផ្ទះប៉ុនរោងដោលអញ្ចេះមែនដូចឥឡូវទេនេះទើបធ្វើ។
ក៖ ផ្ទះឈើក៏ផ្ទះ...?
ខ៖ ឈើពីដើមឈើអើ...ឈើយើងមានទៅរកណាព្រៃស្រោង។
ក៖ ឈើប្រក់ស្សរប្រក់ក្បឿងតា?
ខ៖ ប្រក់ស្សរ។
ក៖ ប្រក់ស្សរ?
ខ៖ ប៉ុនផ្ទះរោងដោល។
ក៖
ហើយ...ដល់ពេលក្រោយមកពេលតាមានប្រពន្ធអីបែកពីប៉ុលពតអីមកផ្ទះហ្នឹង
យ៉ាងម៉េច?

ខ៖ ផ្ទះហ្នឹងបាត់ទៅគេរុះដុតចោលខ្ទេចណុង
យាយទៅដុតអើ...មនុស្សរត់ចោលព្រៃស្មៅដុះពេញតាហ្នឹងភ្លើងព្រៃមកទៅនេះខ្ទេច។
ក៖ អឺម...
ខ៖ គ្មានសល់អីទេហើយណាគេរុះយកទៅធ្វើរណ្តៅត្រង់សេគេនោះ។
ក៖
អូ...ហើយដល់ពេលអញ្ចឹងដល់ពេលដាច់មកបាត់ផ្ទះបាត់អីអស់អញ្ចឹងទៅធ្វើផ្ទះថ្មីទៅ?
ខ៖ ធ្វើរោងនៅបីដើមនោះ។
ក៖ ចាស!
ខ៖ រួចបានមកក្រោយៗមកបានចេះតានេះទៅបានធ្វើបានទ្រើសតិចផ្ទះម៉ែចបានអញ្ចេះបើអស់អាលីងហីនេះអាលីង។
ក៖
ហើយតាដូចអី...ពីឪពុកម្តាយមកក្រៅពីចេះធ្វើស្រែធ្វើអីតាមគាត់មកដូចមានជំនាញអីផ្សេងទៀតតាចេះពីឪពុកម្តាយមក?
ខ៖ គ្មានហ៎ៃមានឡើងតាគ្នោតអីប៉ុណ្ណឹង។
ក៖ ក្ងរស្ករអីចេះហេតា?
ខ៖ ចេះ!
ក៖ ចេះ?
ចុះស្ករអី...ឡើងគ្នោតយកទឹកគ្នោតធ្វើអីអារបៀបធ្វើទឹកគ្នោតជូរអីចេះដែរ?
ខ៖ ចេះពីដើមធ្វើ។
ក៖ ចាស!
ខ៖ ខ្ញុំហាសរំងាស់ល្ងមបានតាចេញស្ករហ្នឹងយូរហាស។
ក៖ ហើយ...ដល់ពេលហើយដូចចេះវេញវល្លិ៍ចេះអី...?
ខ៖ ខ្សែគោអីចេះ។
ក៖ ចេះ?
ហើយអឺម...តាដូចអី...ឪពុកម្តាយអីដូចចងចាំអីឬក៏គាត់បានបង្រៀនតាអីខ្លះដែរពីក្មេងមកហាណា?
ខ៖ ហ៎..មានតាដកស្ទូងហ្នឹងគ្មានអីក្រៅពីឡើងវេញអី...រៃការគ្នោតអីវេញខ្សែគោវេញអីតាប៉ុណ្ណឹង។
ក៖ ហើយតាអឺម...ដូចសព្វថ្ងៃហ្នឹងដូចអី...ទំនេរអីតាចូលចិត្តធ្វើអី?
ខ៖ គ្មានអីទេមានតាអុសភ្លើងយកមកផ្ទះដុតដាំបាយដាំទឹក។
ក៖ ចូលចិត្តស្តាប់ចម្រៀងតា?
ខ៖ ចម្រៀងចូលចិត្តស្តាប់។
ក៖ ភាគច្រើនចម្រៀងម៉ែចតាចូលចិត្តស្តាប់?
ខ៖ បទសាមុតហ្នឹងតាហ្ហង។
ក៖ ស្តាប់តាសាមុតហេណើរ?
ខ៖ សាមុត ប៉ែនរ៉ែនអីហ្នឹងឱ្យតាចម្រៀងពួកហ្នឹងចូលចិត្តស្តាប់ហាស។
ក៖ ចុះសម័យអាឡរ?
ខ៖ ហ៎...ដូចជាមិនសូវចូលហេអាញ្ជាក់អាញ្ជរមិនដឹងស្អីៗ។
ក៖ ហើយតាចូលចិត្តស្តាប់ភ្លេងប្រពៃណីដែរមហារ?
ខ៖ អូ...ហ្នឹងសុទ្ធតាអញ្ចាហើយ មែនតែប៉ុណ្ណឹងហ៎ៃឱ្យត្រូវតែភ្លេងរ៉ាំៗភ្លាមហ្នឹង។
ក៖ អូ...រ៉ាំដែរ?
ខ៖ សប្បាយអញ្ចឹងតា។
ក៖ ចុះច្រៀង?
ខ៖ ច្រៀងមិនសូវចេះទេ។
ក៖ សម្លេងអត់បានហ៎ៃ។

ខ៖ ស្ងាត់ៗចេះជ្រៀងបើសិនមានគេមានឯងដូចរាងស្រែកមិនរួចតាហ្លង។
ក៖ ហើយចុះភ្លេងដូចឧបករណ៍ភ្លេងខ្មែរអីចេះលេងហ៎ាតា?
ខ៖ អត់ទេអត់ចេះ។
ក៖ ចុះមានអ្នកក្នុងគ្រួសារអីគាត់ចេះហ៎?
ខ៖ ក្ងានទេបើសិនជាមានទៅចូលចិត្តណាស់ហើយធម៌
ហើយម្យ៉ាងគេចាក់ដូចពិរោះរបស់គេហាសប្រពៃណីខ្មែរ។
ក៖ ចុះអឺ...ដូចភាគច្រើនអីចូលឆ្នាំអីមួយគ្រួសារមួយអីចូលចិត្តធ្វើអីតា?
ខ៖ មានអីរ៉ាវង់អីល្បែងប្រជាប្រិយតែប៉ុណ្ណឹង។
ក៖ តាលេងល្បែងប្រជាប្រិយដែរណើរ?
ខ៖ អឺ...
ក៖ លេងអីខ្លះល្បែងប្រជាប្រិយចូលឆ្នាំម្តងៗ?
ខ៖ បោះឈូងបោះអង្គញ្ញហ្នឹងហាស។
ក៖ ចាស!
ខ៖ ទាញព្រ័ត្រទាញអីទៅ។
ក៖ ចាស!
ខ៖ ចាស់ៗពីដើមចូលចិត្តតាលេងលាក់កន្សែង។
ក៖ ចាស!
ហើយមួយទៀតមិញថាចូលចិត្តស្តាប់ចម្រៀងចូលចិត្តរ៉ាំចូលចិត្តអីហើយចុះយាយ
ពីអឺ...ដូចថារឿងមួយបរឿងអីហាណាតាចូលចិត្តពិសារអីជាងគេមួយ?
ខ៖ អ្នកស្រែមានអីប្រហើរ ម្ហូរឆាអីហ្នឹង។
ក៖ ចាស! ហើយចេះស្លហេតា?
ខ៖ ខ្ញុំទើបៗឈប់ចុងភៅការតា។
ក៖ អូ...ធ្លាប់ធ្វើចុងភៅការដែលណើស?
ខ៖ ធ្វើ!
ក៖ យូរឆ្នាំហេសបានយូរឆ្នាំហ៎?
ខ៖ យូរហាទើបឈប់ប្រហែលជាបីឆ្នាំហ្នឹងទេ ទ្រាំនឹងក្តៅភ្លើងមិនបាន។
ក៖ មេចុងភៅហ្លងក៏កូនកាំបិត?
ខ៖ ហ៎...កូនកាំបិត។
ក៖ កូនកាំបិតណើស?
កូនកាំបិតហ្នឹងធ្វើអីខ្លះគ្រាន់តាទៅជួយហាន់បន្លែហាន់អីចុងភៅហ៎?
ខ៖ អាំងសាច់អីហ្នឹងហើយជួយឆាឆោជួយអីគេទៅយើងទំនេរអី
មែនស្រួលណាអាធ្វើឆ្នាំងធំ។
ក៖ ចាស!
ខ៖ ទៅមកអាគ្រឿងនេះតិចនោះតិចហ្នឹង។
ក៖ ហើយទៅធ្វើកូនកាំបិតចុងភៅការហ្នឹងតាចេះៗមួយបអីខ្លះមួយការ?
ខ៖ ហ៎...តាមគេកម្មង់ត្រូវការម៉េចអីធ្វើតាមគេ។
ក៖ អញ្ចឹងឱ្យតាមួយបការចេះទាំងអស់?
ខ៖ មិនអស់ទេនៅច្រើនហាស អើ...គិតទៅទៅតាំងពីក្បាលល្ងាច
រួចបានចាប់ស្លដាំហ្នឹងគេហាស
ម៉ោងបីម៉ោងបួនតាំងគេហៅទៅការបានឆ្ងាយទៀតនោះទៅស្ពន់ទៅអីណានោះ។
ក៖ អូ...
ខ៖ ទៅជិតលើនោះទៅក្រចេះជិតអី។
ក៖ ទៅដូចដេកមួយយប់?
ខ៖ មួយយប់ទៅគឺតាដេកហ្លង។
ក៖ ចាស!
ខ៖ បើមិនស្រួលពីរយប់
ទៅដល់ចាប់ផ្តើមដំឡើងរោងដំឡើងអីរៀបចំបានឆ្នាំងហ្នឹងរួចមួយថ្ងៃ

ហើយយប់នោះទៅថាបានដេកមិនបានដេកទៀតត្រូវធ្វើបន្ថែនេះបន្ថែនោះដូចខ្ទឹមដូចអីហ្នឹងបកទៅ អាណាត្រូវចិញ្ចាំៗទៅ។
ក៏ ដូចមួយយប់ទល់ភ្លឺអញ្ចឹងក៏ម៉េច?
ខ៏ មួយយប់ទាល់ព្រឹកហ្នឹងតាហ្គងព្រឹកឡើងបបរអោយគេទៀត។
ក៏ អូ...
ខ៏ មួយខ្ទះហើយពីរខ្ទះទៀត។
ក៏ ហើយអញ្ចឹងយប់មួយយប់អត់ដេកសោះ?
ខ៏ ដេកទេបើទ្រោមអញ្ចឹងទៅហើយដេកមិនសូវបានដេក
ស៊ីនោះវាស៊ីណាស់ទៅហើយមិនខ្វះស៊ីទេ។
ក៏ ហើយតាអើ...រាល់ថ្ងៃចិតជាងហើយទៅវត្តទៅអី?
ខ៏ ទៅដែលអើ..ទៅតាថ្ងៃសីល។
ក៏ ទៅសុំសីលសុំអីតាណើរ?
ខ៏ អឺ...
ក៏ ហើយអើ...សីលតាកាន់សីលប៉ុន្ថាន?
ខ៏ សីលជ្រាំ។
ក៏ សីលជ្រាំ?
ខ៏ សីលជ្រាំបើមិនដឹងហូបជាយទេ។
ក៏ ម៉េចតាពិបាកពេក?
ខ៏ ឃ្លានៗហាស។
ក៏ សីលៗជ្រាំបើហ្នឹងម៉េចល្ងាចឡើងគេឱ្យអត់ជាយ?
ខ៏ អត់ៗល្ងាចអត់ឱ្យស៊ីទេ
មួយថ្ងៃមួយយប់ទាល់មួយយប់ហ្នឹងទាល់មួយព្រឹកឡើងទៀតបានបានស៊ីជាយ។
ក៏
ហើយអឹម...មួយទៀតដូចតាដូចជាអី..មានបងប្អូនសាច់ញាតិណាធ្លាប់ទៅនៅស្រុកក្រៅហេ?
ខ៏ មានកូនថន់ណើរ។
ក៏ បាទ!
ខ៏ កូនថន់នេះទៅកាលណុងទៅថៃ
បើធ្លាប់ស្គាល់ដូចចែសេងដូចសៀកអីអើ..ពីដើមចែសេងសៀកទៅចុងភៅជាមួយគ្នាតើ។
ក៏ ចាស!
ខ៏ គិតហ៊ុនមកដែរ ប៉ុនមិនបានជួបគ្នា។
ក៏ អញ្ចឹងមានបងប្អូនដែលធ្លាប់ទៅថៃ?
ខ៏ មានចៅ។
ក៏ ចៅណើស?
ខ៏ រកស៊ីនៅព្រំដែនណុងហាសហ្ការ៉ូយ
ក៏ អ៉..ទៅធ្វើកម្មករក៏ម៉េច?
ខ៏ ទៅហេ..គេលក់ដូរ។
ក៏ អ៉..ទៅលក់ដូរ? ប៉ុន្ថែដូចកូនចៅអីខ្លួនឯងអត់ដែលមានហេ?
ខ៏ ក្ខានទេ ហ៉ាមានមួយដែលទៅភ្នំពេញអាឡូរ គេទៅកាត់ដេរ។
ក៏ ចាស!
តាអាយុច្រើនធ្លាប់ឆ្លងកាត់សម័យសង្គមរាស្ត្រនិយមឬធ្លាប់ឆ្លងកាត់សម័យប៉ុលពតអីហ៉ាណ៏ា។
ខ៏ សង្គមរាស្ត្រនិយមសប្បាយពេញបន្ទុកហើយកាលណុង។
ក៏ អញ្ចឹងសប្បាយម៉េចខ្លះមើលប្រាប់តិចមើលតា?
ខ៏ សប្បាយដើរពេលទៅណាមកណាអីថាដូចអត់មានបារម្ភ
ពិបាកនៅផ្ទះអីក្ខានទេដើរសេរីហើយ។

ក៖ សុខសុវត្ថិភាពហ៎ណើរជំនាន់ណុង?
ហើយចុះតាបើប្រៀបធៀបពីៗសង្គមរាស្ត្រនិយមមកសម័យអាឡូវម៉េចដែល?
ខ៖ ខុសគ្នាណាស់ខុសមេយហ៊ីដ៏។
ក៖ ខុសៗម៉េចខ្លះ?
ខ៖ ធ្ងរជាងមុនមែនដូចប៉ុលពតហេណាស់។
ក៖ ចាស!
ខ៖ ជំនាន់ប៉ុលពតហ្នឹងហូបាច់យាយទេស្ទាហ្នឹងនៅភ្ជួររាស់។
ក៖ ចាស!
ខ៖ ឥឡូវគេឱ្យSeoung Chhounរកតាមចិត្តទេនេះ។
ក៖ ចាស!
ខ៖ ប្រឹងប្រែងរកប្រឹងបានប៉ុនឯងអ្នកមិនប្រឹងរកទេបានតែប៉ុណ្ណឹង។
ក៖ ចាស!
ខ៖ ដើរសេរីដែលឥឡូវ។
ក៖ ចាស! ហើយមួយទៀតតាពីក្មេងមកដែលធ្លាប់ស្រមៃចង់ធ្វើអីដែរ?
ខ៖ ដូចជាគ្មានទេ
ធ្លាប់តែធ្វើរោងចក្រចេញពីរោងចក្រនោះការប្រពន្ធតាហ្ន
ងបានធ្វើការបានតិចដែរ។
ក៖ ធ្វើការរោងចក្រហ្នឹងធ្វើអីតារោងកាត់ដេររោងចក្រ?
ខ៖ ទេកាលណុងទៅជួសជុលដូចជាធ្វើរបងធ្វើអីហ្នឹងកាលណុងគេចាត់ឱ្យទៅ។
ក៖ ខាងជាងសំណង់រឿយហ៎?
ខ៖ ហេ...មិនទាន់ដល់ណុងទេ។
ក៖ ហ្នឹងឆ្នាំណាតាចាំហ៎?
ខ៖ ហ្នឹងបែបឆ្នាំចិតសិប។
ក៖ ចិតសិបណើស?
ខ៖ អឹម...
ក៖ អឺ...ហើយប៉ុន្ថានឆ្នាំតាធ្វើបានឆ្នាំ?
ខ៖ កាលណុងដូចជាពីរឆ្នាំធ្វើបាតុកម្មសម្តេចហ្នឹងទម្លាក់សម្តេចតាហ្នឹង។
ក៖ ចាស!
ខ៖ បែកខ្ទែកគ្នាត្រឹមហ្នឹងទៅ។
ក៖ កាលណុងទៅធ្វើនៅណានៅភ្នំពេញ?
ខ៖ រោងចក្រយើងហ្នឹង។
ក៖ អូ..រោងចក្រកំពង់ចាមរោងចក្រវាយណកណ្ឌនេះណើរ?
ខ៖ ណុងហី។
ក៖ អ..
ខ៖ ណុងសុទ្ធតាឪពុកខ្ញុំហ៎ធ្វើដំបូង។
ក៖ ចាស!
ខ៖ កាប់ដីទៅអាណារៀបឥដ្ឋរៀបអីទៅអាណាអីទៅ។
ក៖
ហីអឹម..ដូចជាអឹម..ប្រហែលជាចុងក្រោយដូចជាតាមានអីដូចផ្តាំផ្ញើរដល់កូនចៅ
អីហាណាបើសិនជាកូនចៅបានស្តាប់លឺសម្លេងរបស់តាអីតាមានពាក្យពេចន៍អី
ដើម្បីផ្តាំផ្ញើរដល់ពួកគាត់?
ខ៖ ត្រាន់ផ្តាំផ្ញើកូនចៅសារក្រោយ
កុំឱ្យបែកបាក់គ្នាត្រូវសាមគ្គីគ្នាចេះស្រឡាញ់គ្នាដូចសព្វថ្ងៃហ្នឹងវាបានហើយ។
ក៖ ចាស! ប៉ុណ្ណឹងហ៎តាណើរអត់មានអីទៀត?
ខ៖ គ្មានហ៎។
ក៖
ខេអញ្ចឹងអឺ..ចុងក្រោយសូមអរគុណតាបានឱ្យខ្ញុំសម្ភាសហើយអឺ...មួយទៀតដល់

ពេលអឺ...ការសម្ភាសហ្នឹងបើសិនជាអឺ...យើងសុំអនុញ្ញាតពីតាបើសិនជាយកសម្លេងហ្នឹងទៅដាក់លើវេបសាយរបស់សាលាអីបានហេតា?
ខ៖ បានអត់អីទេ។
ក៖ ហើយមួយទៀតប្រហែលជាចប់ទៅសុំថតរូបតាមួយបុស្តិ៍ពីរប៉ុស្តិ៍បានហ៎?
ខ៖ បាន។
ក៖ ចាស! អូខេ អញ្ចឹងខ្ញុំអរគុណច្រើនតា។